**ប្រការ២៖**ត្រូវភ្ជាប់ជាមួយឯកសារសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ឬ មណ្ឌលសុខភាពដែលចេញដោយគ្រូពេទ្យ។

**ប្រការ៣៖**ក្នុងករណីខកខាននៃការបង់ថវិកាសមាជិករយៈពេល ០១ឆ្នាំ នោះមិនបានទទួលអត្ថប្រយោជន៍ ពីសមាគម ដូចបានចែងក្នុងជំពូក៣

**ប្រការ៤៖** យោងតាមប្រការ៣ សមាជិកដែលខកខាន នឹងទទួលបាន អត្ថប្រយោជន៍ឡើងវិញក្នុងរយៈពេល០៦ខែ ក្រោយបន្ទាប់ពីការបង់ថវិកាឡើងវិញ។

**ប្រការ៥៖** ចំពោះសមាជិកដែលទទួលមរណៈភាព ត្រូវមានលិខិតមរណៈភាព ពីមន្ទីរពេទ្យ ឬ អាជ្ញាធរដែនដី (មិនលើសពី០៣ខែ)។

**ប្រការ៦៖** ត្រូវមាន លិខិតផ្តល់សិទ្ធិទទួលប្រាក់ឧបត្ថម្ភ ពេលទទួលមរណភាព(បណ្តាំមរណៈភាព)។

## ជំពូក៥
## ការគ្រប់គ្រង និងការប្រើប្រាស់ថវិកា

**ប្រការ១៖**ថវិកាសមាជិកភាពដែលទទួលបានពីការបង់ថវិកាប្រចាំខែ និងសិទ្ធិចូលជាសមាជិកគ្រប់ប្រភេទត្រូវទទួលដោយបុគ្គលិកសមាគម ដោយមានចេញជាវិក័យប័ត្រទទួលប្រាក់ដែលមានចំនួន ០៣សន្លឹក ។ វិក័យប័ត្រ១សន្លឹករក្សាទុកដោយសមាជិកផ្ទាល់និង០២សន្លឹករក្សទុកនៅសមាគម។រាល់ថវិកាដែលបានបង់ចូលសមាគមសម្រាប់សមាជិកភាពគ្រប់ប្រភេទមិនអាចដកវិញបានទេបើទោះបីជាមានការផ្លាស់ប្តូរប្រភេទសមាជិករឺលាឈប់ក៏ដោយ ។

**ប្រការ២៖**ថវិកាសមាជិកភាពទាំងអស់ត្រូវបានគ្រប់គ្រងដោយសមាគម(រក្សាទុកនៅក្នុងគណនីសន្សំរបស់ធនាគារ ស្របច្បាប់ និងត្រឹមត្រូវ)

**ប្រការ៣៖** ការប្រើប្រាស់ថវិកាសមាជិកភាពអាចដកប្រើប្រាស់បានចំនួន១០%នៃប្រាក់ចំណូលប្រចាំខែនីមួយៗ សម្រាប់ការចំណាយផ្នែកកិច្ចការរដ្ឋបាល (ទូរដាក់ឯកសាររបស់សមាជិកភាពប័ណ្ណសំគាល់សមាជិកភាព ថង់ប្លាស្ទិចសម្រាប់ ច្រកប័ណ្ណស្រោមសំបុត្រឮការបិទរូបថត តាំប៉ុងឯកសារនិងវិក័យប័ត្រចំណូលចំណាយ។ល។ឬក្នុងករណីមាន តម្រូវការចាំបាច់ និងជាក់ស្តែង ។

**ប្រការ៤៖** ឧបត្ថម្ភដល់សមាជិកដែលរស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍ ពេលទទួលមរណៈភាពចំនួន៣០០, ០០០ រៀល (សម្រាប់សមាជិកដែលពេញសិទ្ធិរយៈពេល០៦ខែ។

**ប្រការ៥៖** ឧបត្ថម្ភចំនួន២.០០០រៀលក្នុងមួយថ្ងៃដល់សមាជិកដែលរស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍ ក្នុងករណីសម្រាកពេទ្យព្យាបាល ក្នុងគ្រប់មន្ទីរពេទ្យរដ្ឋក្នុង០១ថ្ងៃ ដោយគិតចាប់ថ្ងៃទី១នៃការចូលសម្រាកក្នុងមន្ទីរពេទ្យ។

## ជំពូក៦
## និតិវិធីក្នុងការប្រើប្រាស់ថវិកាសមាជិកភាព

រាល់ការចំណាយទាំងផ្នែករដ្ឋបាល និង សមាជិកភាពត្រូវមានការឯកភាពពី គណៈគ្រប់គ្រងសមាគមនិងក្នុងករណីមានតម្រូវការចាំបាច់ និងជាក់ស្តែងត្រូវមានការឯកភាពពីគណៈកម្មាធិការកណ្តាល។ រាល់ការចំណាយនានាត្រូវមានឯកសារជាផ្លូវការគ្រប់គ្រាន់ដើម្បីទូទាត់ និងរាយការណ៍ជូនសមាជិកពេញសិទ្ធទាំងងអស់ឱ្យបានជ្រាបជាព័ត៌មាននាកិច្ចប្រជុំសមាជិកប្រចាំឆ្នាំ ។

## ជំពូក៦
## អវសាន្តសមាជិកភាព

**ប្រការ១៖** រាល់សមាជិកមានសិទ្ធិផ្លាស់ប្តូរប្រភេទសមាជិកឬលាឈប់ពីសមាជិកសមាគមបានដោយស្ម័គ្រចិត្ត និង ត្រូវផ្តល់ព័ត៌មានជូនសមាគមជាលាយល័ក្ខអក្សរ។

**ប្រការ២៖**សមាជិកដែលបាត់ដំណឹងឬទំនាក់ទំនងមិនបានក្នុងរយៈ១ ឆ្នាំ ឬ ស្លាប់ត្រូវអស់សិទ្ធិជាសមាជិករបស់សមាគមដោយស្វ័យប្រវត្តិ

**ប្រការ៣៖**រាល់ប្រការណាដែលផ្ទុយពីគោលការណ៍សមាជិកភាពនេះ ត្រូវទុកជាមោឃៈ ។

## ជំពូក៦
## ការកែប្រែគោលការណ៍សមាជិកភាព

គោលការណ៍សមាជិកភាពនេះនឹងត្រូវបានកែប្រែតាមស្ថានភាពជាក់ស្តែង និង ចាំបាច់នៅក្នុងកិច្ចប្រជុំឆ្នាំរបស់ សមាជិកភាពប្រជុំពិសេសរបស់ គណៈគ្រប់គ្រងឬគណៈកម្មាធិការកណ្តាលរបស់សមាគម។

**ធ្វើនៅភ្នំពេញ, ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥**

**នាយិកាប្រតិបត្តិ**

ហាន សៀងហ៊ាន

សមាគមអ្នកប្រើប្រាស់ថ្នាំពន្យារជីវិត
ARV Users Association

**សមាគមអ្នកប្រើប្រាស់ថ្នាំពន្យារជីវិត**

ARV Users Association

# គោលការណ៍ សមាជិកភាព

# The Membership's Policy



**លេខទូរស័ព្ទទំនាក់ទំនង៖**

ការិយាល័យកណ្តាលភ្នំពេញ៖ 023 222 054
តំបន់អនុវត្តន៍ការងារខេត្តកំពង់ចាម៖ 017 337 217

Email: info@auacambodia.org
Website: auacambodia.org

Edition: 2015, December

## សេចក្ដីផ្ដើម

ដើម្បីឱ្យការអនុវត្តន៍សកម្មភាពរបស់ខ្លួនកាន់តែរឹងមាំប្រសិទ្ធភាព និង និរន្តភាព សមាគមបានផ្តួចផ្តើម និង បង្កើតឱ្យមានបណ្ដាញសមាជិកភាព នៅឆ្នាំ២០០៦ ក្នុងគោលបំណងប្រមូលព័ត៌មាន និងសំលេងក្នុងការស្វែងរកការគាំទ្រនិងដើម្បីឆ្លើយតបតាមតម្រូវការរបស់អ្នករស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការសមាគមបានផ្តួចផ្តើម និង បង្កើតគោលការណ៍សមាជិកភាពដើម្បីគ្រប់គ្រង និងដឹកនាំរាល់សកម្មភាពការងារដែលពាក់ព័ន្ធ នឹងសមាជិកគ្រប់រូបឱ្យមានភាពច្បាស់លាស់ត្រឹមត្រូវសមភាពតម្លាភាពនិងអត្ថប្រយោជន៍នានាក្នុងការចូលជាសមាជិករបស់សមាគម។

គោលការណ៍សមាជិកភាពថ្មីរបស់សមាគមអ្នកប្រើប្រាស់ថ្នាំពន្យារជីវិតត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ចាប់ពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ នាកិច្ចប្រជុំពេញអង្គប្រចាំឆ្នាំ របស់សមាជិកភាពដោយមានការចូលរួមពីក្រុមប្រឹក្សាភិបាល ដូចមានចែងខាងក្រោម:

## ជំពូក១
## លក្ខខណ្ឌជាសមាជិកភាព

**ប្រការ១៖**ការចូលជាសមាជិកត្រូវធ្វើឡើងដោយស្មគ្រ័ចិត្តចំពោះប្រជាពលរដ្ឋទូទៅ ដែលមានអាយុចាប់ពី១៨ឆ្នាំឡើង ។

**ប្រការ២៖** មិនរើសអើងពូជសាសន៍ សាសនា វប្បធម៌ ពណ៌សម្បុណ៌ និង សេដ្ឋកិច្ចសង្គម ។

**ប្រការ៣៖** មិនបម្រើឱ្យផលប្រយោជន៍ការងាររបស់គណបក្សនយោបាយណាមួយ។

**ប្រការ៤៖** ត្រូវបំពេញទម្រង់ឯកសារ និង លក្ខខណ្ឌផ្សេងៗដូចខាងក្រោម:

ក/ពាក្យសុំចូលជាសមាជិក, ជីវប្រវត្តិសង្ខេប និង លិខិតបណ្ដាំមរណៈភាព។

ខ/រូបថតទំហំ(3x4)ចំនួន០២សន្លឹក និង (4x6)ចំនួន០២សន្លឹក។

គ/ទទួលបានបណ្ណ័សំគាល់សមាជិកភាព ០១សន្លឹក។

## ជំពូក២
## ប្រភេទសមាជិក

**ប្រការ១៖** ប្រភេទសមាជិកត្រូវបានបែកចែកជាបីប្រភេទផ្សេងគ្នា ។

ក/សមាជិកសកម្មជាសមាជិកដែលរស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍។

ខ/សមាជិកទ្រទ្រង់ជាសមាជិកដែលរស់នៅឬមិនរស់នៅមេរោគអេដស៍/ជំងឺអេដស៍។

គ/សមាជិកកិត្តិយសជាសមាជិកដែលរស់នៅ ឬ មិនរស់នៅមេរោគអេដស៍/ជំងឺអេដស៍។

**ប្រការ២៖** ការបង់ថវិកា

ក/គ្រប់ប្រភេទសមាជិកមិនត្រូវបង់ថវិកាសុំសិទ្ធិចូលជាសមាជិកទេ។

ខ/សមាជិកសកម្ម: បង់ថវិកាចំនួន ១២,០០០ រៀល (មួយម៉ឺនពីរពាន់រៀលគត់) ក្នុងមួយឆ្នាំ។

គ/សមាជិកទ្រទ្រង់បង់ថវិកាចំនួន៤២,០០០រៀល (បួនម៉ឺនពីរពាន់រៀលគត់)ក្នុងមួយឆ្នាំ។

ឃ-សមាជិកកិត្តិយសបង់ថវិកាចំនួន៣៥,០០០រៀល(សាមសិបប្រាំពាន់រៀលគត់) ក្នុងមួយខែ។

## ជំពូក៣
## អត្ថប្រយោជន៍

**ប្រការ១៖**

**១.សមាជិកសកម្ម**

ក/ទទួលបានបណ្ណ័សំគាល់សមាជិក ០១សន្លឹក

ខ/ទទួលបានថវិកាឧបត្ថម្ភប្រចាំថ្ងៃចំនួន២,០០០រៀល(ពីរពាន់រៀលគត់) ក្នុងករណីសម្រាកពេទ្យព្យាបាលជម្ងឺ ក្នុងគ្រប់មន្ទីរពេទ្យរដ្ឋក្នុង០១ថ្ងៃ ដោយគិតចាប់ថ្ងៃទី១ នៃការចូលសម្រាកក្នុងមន្ទីរពេទ្យ។ សម្រាប់សមាជិកដែលរស់នៅជាមួយមេរោគអេដស៍។

គ/ទទួលបានថវិកាឧបត្ថម្ភក្នុងករណី ទទួលមរណៈភាព ចំនួន ៣០០,០០០រៀល(បីរយពាន់រៀលគត់)។

ឃ/មានសិទ្ធិបោះឆ្នោត និង ឈរឈ្មោះជាតំណាងគណៈកម្មាធិការកណ្ដាលរបស់សមាគម។

ង/មានសិទ្ធិចូលរួមក្នុងសកម្មភាពការងាររបស់សមាគម។

ច/ចូលរួមផ្តល់មតិយោបល់ដើម្បីកែលំអរដល់សមាគម។

ឆ/ទទួលបានព័ត៌មានផ្សេងៗពីសមាគម

**២-សមាជិកទ្រទ្រង់**

ក/ទទួលបានបណ្ណ័សំគាល់សមាជិក ០១សន្លឹក

ខ/ទទួលបានលិខិតថ្លែងអំណរគុណ ឬ បណ្ណ័សរសើរ ។

គ/ទទួលបានថវិកាឧបត្ថម្ភប្រចាំថ្ងៃចំនួន២,០០០រៀល(ពីរពាន់រៀលគត់) ក្នុងករណីសម្រាកពេទ្យព្យាបាលជម្ងឺ ក្នុងគ្រប់មន្ទីរពេទ្យរដ្ឋក្នុង០១ថ្ងៃ ដោយគិតចាប់ថ្ងៃទី១នៃការចូលសម្រាកក្នុងមន្ទីរពេទ្យ។ សម្រាប់សមាជិកដែលរស់នៅជាមួយមេរោគអេដស៍។

ឃ/ទទួលបានថវិកាឧបត្ថម្ភក្នុងករណី ទទួលមរណៈភាព ចំនួន ៣០០.០០០រៀល(បីរយពាន់រៀលគត់) សម្រាប់សមាជិកដែលរស់នៅជាមួយមេរោគអេដស៍។

ង/មានសិទ្ធិបោះឆ្នោត និង ឈរឈ្មោះជាតំណាងគណៈកម្មាធិការកណ្ដាលរបស់សមាគម។

ច/មានសិទ្ធិចូលរួមក្នុងសកម្មភាពការងាររបស់សមាគម។

ឆ/ចូលរួមផ្តល់មតិយោបល់ដើម្បីកែលំអរដល់សមាគម។

ជ/ទទួលបានព័ត៌មានផ្សេងៗពីសមាគម។

**៣-សមាជិកកិត្តិយស**

ក/ទទួលបានបណ្ណ័សំគាល់សមាជិក ០១សន្លឹក។

ខ/ទទួលបានលិខិតថ្លែងអំណរគុណ ឬ បណ្ណ័សរសើរ។

គ/ទទួលបានថវិកាឧបត្ថម្ភប្រចាំថ្ងៃចំនួន២,០០០រៀល(ពីរពាន់រៀលគត់) ក្នុងករណីសម្រាកពេទ្យព្យាបាលជម្ងឺ ក្នុងគ្រប់មន្ទីរពេទ្យរដ្ឋក្នុង០១ថ្ងៃ ដោយគិតចាប់ថ្ងៃទី១ នៃការចូលសម្រាកក្នុងមន្ទីរពេទ្យ។ សម្រាប់សមាជិកដែលរស់នៅជាមួយមេរោគអេដស៍។

ឃ/ទទួលបានថវិកាឧបត្ថម្ភក្នុងករណី ទទួលមរណៈភាព ចំនួន ៣០០.០០០រៀល(បីរយពាន់រៀលគត់) សម្រាប់សមាជិកដែលរស់នៅជាមួយមេរោគអេដស៍។

ង/មានសិទ្ធិបោះឆ្នោត និង ឈរឈ្មោះជាតំណាងគណៈកម្មាធិការកណ្ដាលរបស់សមាគម។

ច/មានសិទ្ធិចូលរួមក្នុងសកម្មភាពការងាររបស់សមាគម។

ឆ/ចូលរួមផ្តល់មតិយោបល់ដើម្បីកែលំអរដល់សមាគម។

ជ/ទទួលបានព័ត៌មានផ្សេងៗពីសមាគម។

## ជំពូក៤
## លក្ខខណ្ឌផ្សេងៗនៃការទទួលបានអត្ថប្រយោជន៍

**ប្រការ១៖**សមាជិកថ្មីដែលបានចូលជាសមាជិករយៈពេល ០៦ខែ (ប្រាំមួយខែ)ឡើងទៅទើបអាចទទួលអត្ថប្រយោជន៍ដូចក្នុងជំពូក៣។